FUTURE FORUM
Public. Policy. Forward.

# ទិដ្ឋភាពរួម និងការវិភាគស្ថានភាពនយោបាយកម្ពុជានាពេលបច្ចុប្បន្ន

ខែកុម្ភៈ ឆ្នាំ២០១៧

## ១. សេចក្តីសង្ខេប

អត្ថបទនេះផ្តល់នូវទិដ្ឋភាពរួមសង្ខេប និងការវិភាគស្ថានភាពនយោបាយនៅកម្ពុជានាពេលបច្ចុប្បន្ន ដោយផ្តោតលើយុទ្ធសាស្ត្រដែលតួអង្គសំខាន់នីមួយៗប្រើប្រាស់ និងនិន្នាការប្រវត្តិសាស្ត្រ ដែលនៅពីក្រោយយុទ្ធសាស្ត្រទាំងនេះ ព្រមទាំងហានិភ័យដែលអាចនឹងកើតឡើងសម្រាប់ប្រទេសកម្ពុជា។ ជាដំបូង អត្ថបទនេះនឹងផ្តល់ទិដ្ឋភាពរួមសង្ខេបស្តីពីការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០១២ និងការបោះឆ្នោតជាតិ ឆ្នាំ២០១៣ បន្ទាប់មកនឹងសង្ខេបពីការវិវឌ្ឍនយោបាយនានា ជាពិសេសឥទ្ធិពលនៃការគំរាមកំហែងទៅលើគណបក្សប្រឆាំង ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៥ និងបន្តរហូតមកដល់បច្ចុប្បន្ន។ ជាចុងក្រោយ អត្ថបទនេះនឹងវិភាគលើយុទ្ធសាស្ត្រផ្សេងៗ ដែល គណបក្សធំៗទាំងពីរ គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ប្រើប្រាស់ មុននឹងសង្ខេបពីហានិភ័យជាក់លាក់ដែលអាចនឹងកើតមានឡើងសម្រាប់ប្រទេសកម្ពុជា ប្រសិនបើស្ថានភាពនយោបាយ នៅតែបន្តដើរទៅតាមទំនោរនេះ។ អត្ថបទនេះសរសេរដោយវេទិកាអនាគត ដែលជាវិទ្យាស្ថានគោលនយោបាយសាធារណៈ ឯករាជ្យ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥។[1]

## ២. សេចក្តីផ្តើម - ក្តីសង្ឃឹមថ្មី៖ ការបោះឆ្នោតឆ្នាំ២០១២ និង២០១៣

នៅក្នុងក្រសែភ្នែកអ្នកតាមដានស្ថានការណ៍ និងអ្នកបោះឆ្នោតភាគច្រើន ការបោះឆ្នោតក្នុងឆ្នាំ២០១២ និង២០១៣ បានផ្តល់ក្តីសង្ឃឹមយ៉ាងច្រើនសម្រាប់ពួកគេ។ ដំបូង គណបក្សសម រង្ស៊ី របស់លោក សម រង្ស៊ី បានបង្រួបបង្រួមជាមួយនឹងគណបក្សសិទ្ធិមនុស្ស របស់លោក កឹម សុខា ដើម្បីបង្កើតជាគណបក្សប្រឆាំងតែមួយរួមគ្នា។[2] ក្រោយមកទៀត ក្នុងឆ្នាំ២០១៣ ក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា

---

[1] សម្រាប់សំណួរផ្សេងៗទាក់ទងនឹងអត្ថបទនេះ សូមទាក់ទងតាមរយៈអ៊ីម៉ែល៖ info@futureforum.asia ។ អត្ថបទនេះជាសេចក្តីសង្ខេបនៃអត្ថបទវិភាគទាំងមូលដែលផ្តល់ការវិភាគយ៉ាងស៊ីជម្រៅមួយ។ សូមទាក់ទងវេទិកាអនាគតដើម្បីទទួលបានអត្ថបទទាំងមូល។

[2] វង់ សុខេង និងប្រ៊ីហ្គែត ឌីសឺតូ ,'គណបក្សពីរនឹងបង្កើតចលនាប្រជាធិបតេយ្យដើម្បីសង្គ្រោះជាតិ', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ http://bit.ly/2dkgjHG ។

ក្រុមយុវជននៅកម្ពុជាដែលពុំសូវមានការចូលរួមពីមុនមក បានធ្វើការទាមទារឲ្យមានការផ្លាស់ប្តូរ ពួកគេបានធ្វើសកម្មភាពយ៉ាងក្លៀវក្លា និងចាប់ផ្តើមធ្វើឲ្យមានការប្រែប្រួលនៃរបបគ្រប់គ្រងតាមបែបអត្តាធិបតេយ្យ។[3]

បើទោះបីជាមានការសង្ស័យដ៏ច្រើនសន្ធឹកសន្ធាប់ស្តីពីការបន្លំសន្លឹកឆ្នោត និងការបំភិតបំភ័យអ្នកបោះឆ្នោតជាទូទៅ ដែលក្រុមអ្នកសង្កេតការណ៍សង្កេតឃើញយ៉ាងណាក្តី[4] គណបក្សប្រជាជនក៏នៅតែអាចក្តោបក្តាប់អំណាចដដែល ដោយទទួលបានអាសនៈចំនួន៦៨ ទល់នឹងគណបក្សសង្គ្រោះជាតិចំនួន៥៥។[5] ដោយមានការធ្លាក់ចុះពី ៩០ អាសនៈ ការប្រែប្រួលដ៏គំហុកនេះបានបង្ហាញពីការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពដែលអាចគួរឲ្យជឿជាក់របស់គណបក្សប្រជាជន ទំនុកចិត្តរបស់បក្ស និងមណ្ឌលឈរឈ្មោះរបស់បក្ស។ ប៉ុន្តែគណបក្សសង្គ្រោះជាតិជឿជាក់ ថាខ្លួនបានឈ្នះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាត ហើយថាបក្សរបស់ខ្លួនឈ្នះភ្លូកទឹកភ្លូកដី ប្រសិនបើការបោះឆ្នោតនោះត្រូវបានធ្វើឡើងដោយសេរី និងយុត្តិធម៌យ៉ាងពិតប្រាកដ។[6] នៅពេលដែលភាពតានតឹងកាន់តែរីករាលដាល គេឃើញមានយន្តហោះយោធាជាច្រើនហោះក្រវែល និងរថពាសដែកជាច្រើនបានធ្វើដំណើរឆ្ពោះទៅកាន់រាជធានី[7] គណបក្សសង្គ្រោះជាតិ និងអ្នកគាំទ្រខ្លួនជាច្រើនបានប្រឈមមុខដាក់គ្នាជាមួយគណបក្សប្រជាជនដែលទទួលបានជ័យជម្នះដ៏ស្តួចស្តើងក្រោយការប្រកាសជាផ្លូវការ ដោយបានប្រមូលផ្តុំគ្នាធ្វើបាតុកម្មដែលពុំធ្លាប់មានពីមុនមក។[8]

ជាងនេះទៀត គណបក្សសង្គ្រោះជាតិបានបដិសេធទទួលយកអាសនៈរបស់ខ្លួននៅក្នុងសភា ដរាបណាការទាមទាររបស់ខ្លួនមិនត្រូវបានដោះស្រាយ រួមមាន៖ បង្កើតឲ្យមានគណៈកម្មការស៊ើបអង្កេតលើភាពមិនប្រក្រតីជុំវិញការឆ្នោតឲ្យបានច្បាស់លាស់ និងប្រកបដោយឯករាជ្យភាព។[9] ថ្វីបើមានការបង្ក្រាបមួយបានកើតឡើងកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ដែលបានបណ្តាលឲ្យបុរសម្នាក់ស្លាប់ដោយសារតែគ្រាប់កាំភ្លើង និង

---

[3] ប៉ាក់ម៉ែស្វាង៉ាន ប៉ុន្ណូឌូរ៉ែ , `យុវជនខ្មែរបញ្ចេញសាច់ដុំក្នុងការបោះឆ្នោត´, វិទ្យុអាស៊ីសេរី, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៣, http://bit.ly/2dxd8uA។

[4] គណកម្មការធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល), `លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា´, (របាយការណ៍ប្រចាំឆ្នាំ២០១៣) ភ្នំពេញ ខែមេសា ឆ្នាំ២០១៤ , ទំព័រ ១៨ ដល់ ២២, http://bit.ly/2e1To2Z។

[5] ___, គណបក្សប្រឆាំងធំកើនអាសនៈ , *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ http://bit.ly/2eB0o8A។

[6] ស្ទួន វ៉ារ៉ែល, `គណបក្សប្រឆាំងអះអាងពីជ័យជម្នះដោយសំឡេងភាគច្រើន´, *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣, http://bit.ly/2dY44OI ។

[7] ប៉ាក់ម៉ែស្វាង៉ាន ប៉ុន្ណូឌូរ៉ែ និងសាមៀន យុន, `មេបក្សប្រឆាំងរិះគន់ការបង្កើនកម្លាំងយោធានៅក្នុងរាជធានីភ្នំពេញ´, វិទ្យុអាស៊ីសេរី ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ http://bit.ly/2e3YDlb។

[8] ខែត ហុឌដែល, `ការតវ៉ាប្រឆាំងនឹងការបោះឆ្នោតនៅកម្ពុជានៅភ្នំពេញ´, *The Guardian,* ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣, http://bit.ly/2eoIrFF។

[9] វង់ សុខឃេង, `ព្រះមហាក្សត្រកោះប្រជុំសភាលើកដំបូងនៅថ្ងៃទី ២៣ ខែកញ្ញា´, *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣, http://bit.ly/2eihN6x ។

មនុស្សមួយចំនួនរងរបួសជាទម្ងន់ក្តី[10] មហាបាតុកម្មនោះក៏នៅតែបន្តធ្វើឡើងដោយអហិង្សាអស់ជាច្រើនខែ រហូតដល់ដើមខែមករា ឆ្នាំ២០១៤[11] នៅពេលដែលកម្មកររោងចក្រកាត់ដេរ និងសហជីពជាច្រើនបានរួមកម្លាំងជាមួយនឹងគណបក្សសង្គ្រោះជាតិ។[12] នៅខណៈពេលនោះ អាជ្ញាធរបានបាត់បង់ភាពអត់ធ្មត់៖ កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលបានបាញ់ប្រហារមកលើក្រុមកម្មករកាត់ដេរដែលធ្វើបាតុកម្ម បណ្តាលឲ្យមានអ្នកស្លាប់ចំនួនបួននាក់ និងរបួសជាច្រើននាក់។[13] លើសពីនេះទៀត អាជ្ញាធរបានបំបែកអ្នកគាំទ្រ និងសកម្មជនគណបក្សសង្គ្រោះជាតិ ពីមូលដ្ឋានប្រមូលផ្តុំរបស់ពួកគេនៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ ហើយបានហាមឃាត់រាល់ការធ្វើបាតុកម្មគ្រប់ប្រភេទនៅតាមដងផ្លូវ ដែលធ្វើឲ្យលោក សម រង្ស៊ី និងលោក កឹម សុខា ត្រូវសម្ងំលាក់ខ្លួនមួយរយៈ។[14] អំពើហិង្សានេះពិតជាបានសម្រេចតាមគោលបំណងមែន៖ បាតុករត្រូវបានរំសាយ នៅខណៈដែលគណបក្សសង្គ្រោះជាតិកាន់តែខ្សោយទៅៗ និងត្រូវបានទុកឲ្យនៅប្រវេះប្រវាស់ដោយគ្មានយុទ្ធសាស្ត្រជាក់លាក់។

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ប្រហែលមួយឆ្នាំក្រោយទំនាស់ការបោះឆ្នោត លោក សម រង្ស៊ី បានធ្វើកិច្ចព្រមព្រៀងជាមួយនឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីបញ្ចប់ភាពទាល់ច្រកផ្នែកនយោបាយ។[15] តំណាងរាស្ត្រមកពីគណបក្សសង្គ្រោះជាតិនឹងបញ្ចប់ពហិការការចូលរួមប្រជុំសភារយៈពេល ១០ខែ របស់ខ្លួន ហើយទទួលយកអាសនៈ និងឈប់តវ៉ាប្រឆាំងយ៉ាងស្វាត់ៗ ចំពោះលទ្ធផលបោះឆ្នោត ជាមួយនឹងការសន្យាថានឹងមានកំណែទម្រង់បោះឆ្នោតមុនការបោះឆ្នោត ឆ្នាំ២០១៨ ហើយនឹងព្រមទទួលកាន់ដំណែងសំខាន់ៗមួយចំនួននៅក្នុងរដ្ឋសភា។[16] គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិបានចាប់ផ្តើម "វប្បធម៌សន្ទនា" ក្នុងន័យជំរុញឲ្យមានកិច្ចសហប្រតិបត្តិការ ជាជាងការប្រឆាំងគ្នារវាងគណបក្សទាំងពីរ តែវប្បធម៌សន្ទនានេះដូចជាត្រូវបរាជ័យបន្ទាប់ពេលត្រឹមតែមួយឆ្នាំក្រោយមក។

## ៣. ព្រឹត្តិការណ៍ថ្មីៗ៖ ចាប់ពីឆ្នាំ២០១៤

បើសង្កេតមើលចាប់ពីអំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០១៣ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជារបស់គាត់ ទំនងដូចជាគ្រប់គ្រងស្ថានភាពបានឡើងវិញនៅពាក់កណ្តាលឆ្នាំ២០១៤។

---

[10] ___, 'ការតវ៉ាកាន់តែហិង្សា', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣, http://bit.ly/2e40Tsl។

[11] https://www.youtube.com/watch?v=Om5NulU5nko.

[12] ស្តេ វ៉ររ៉ែល មុំ គន្ធា និងមាស សុខជា, 'ការតវ៉ាផ្សេងៗជួបប្រសព្វគ្នា' *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ http://bit.ly/2e3ZceH ។

[13] ឈាង សុខា, ស្ទែន តៃហាន់ និងស្តេ វ៉ររ៉ែល ការបង្ក្រាបធ្វើឲ្យមានអ្នកស្លាប់, *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://bit.ly/2dY6w81។

[14] ប៉ារ៉ាមែស្វារ៉ាន ប៉ុន្នូឌូរ៉ៃ និងសាមៀន យុន, 'មេដឹកនាំបក្សប្រឆាំងនៅកម្ពុជាលាក់ខ្លួនមានការបង្ក្រាបលើបាតុករ', វិទ្យុអាស៊ីសេរី, ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ http://bit.ly/2eMbqqT។

[15] មាស សុខជា និងខេវិន ផូណៃ, 'មួយឆ្នាំក្រោយការបោះឆ្នោត', *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ http://bit.ly/2egj22v។

[16] ប្រភពដូចខាងលើ។

កិច្ចព្រមព្រៀងនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៤ ខ្វះខាតនូវព័ត៌មានលម្អិតជាច្រើន ដែលនឹងអាចធ្វើឲ្យកិច្ចព្រមព្រៀងនោះកាន់តែរឹងមាំ ហើយជាជាងការនិយាយពីកំណែទម្រង់ដែលមិនច្បាស់លាស់ កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលជាការទាមទារយ៉ាងសំខាន់មួយរបស់គណបក្សសង្រោះជាតិ មើលទៅហាក់នៅឆ្ងាយពីកំណែទម្រង់បោះឆ្នោតយ៉ាងពិតប្រាកដ ដែលនឹងអាចធានាបាននូវការបោះឆ្នោតដោយសេរី និងយុត្តិធម៌ក្នុង ឆ្នាំ២០១៨។

មួយវិញទៀត គណបក្សប្រជាជនកម្ពុជាអាចធ្វើឲ្យតំណាងរាស្រ្តគណបក្សសង្គ្រោះជាតិព្រមទទួលយកអាសនៈរបស់ខ្លួននៅក្នុងរដ្ឋសភា ដូច្នេះធ្វើឲ្យរដ្ឋាភិបាលអាចស្តារទំនុកចិត្តបានឡើងវិញ ព្រមទាំងអាចបង្រ្កាបបាតុកម្មតាមដងផ្លូវដែលបន្តរុកគួនរដ្ឋាភិបាលចាប់តាំងពីការបោះឆ្នោតមក ដោយមិនចាំបាច់លះបង់អ្វីច្រើននោះទេ។ ប៉ុន្តែនៅក្នុងឆមាសទី២ ឆ្នាំ២០១៥ ចុងក្រោយនេះ មានការបង្រ្កាបយ៉ាងកម្រោល និងដោយពុំបានរំពឹងទុកមកលើគណបក្សសង្គ្រោះជាតិ ដោយរួមមានទាំងការប្រើប្រាស់អំពើហិង្សា ការបំភិតបំភ័យ និងការយាយីតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀត ការបង្រ្កាបនេះកើតឡើងដោយគ្មានការរំពឹងទុក ដោយហេតុថាមិនមានការព្រមាន និងសញ្ញាបង្ហាញឲ្យច្បាស់លាស់ជាមុន ការបង្រ្កាបពាក់កណ្តាលអាណត្តិមួយនេះបានបន្តកើតឡើងតាំងពីដើមដល់ចប់នៅក្នុងប្រវត្តិសាស្រ្តនយោបាយថ្មីៗរបស់កម្ពុជា។

ដំបូង កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ សកម្មជនគណបក្សសង្គ្រោះជាតិមួយចំនួនត្រូវបានតុលាការផ្តន្ទាទោសពីបទ "កុប្បកម្ម" ដោយសារតែបានចូលរួមក្នុងការតវ៉ាប្រឆាំងនឹងរដ្ឋាភិបាលក្នុងឆ្នាំ ២០១៤។[17] បន្ទាប់មក កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ សមាជិកព្រឹទ្ធសភាដ៏សកម្មរបស់គណបក្សសម រង្ស៊ី[18] លោកហុង សុខហ៊ួរ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន រយៈពេលពីរថ្ងៃបន្ទាប់ពីរូបលោកត្រូវបានលោកនាយករដ្ឋមន្រ្តី ហ៊ុន សែនចោទប្រកាន់ពីបទក្បត់ជាតិ[19] និងត្រូវបានចោទប្រកាន់ពីបទក្លែងឯកសារសាធារណៈ និងញុះញង់។[20] កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៥ តំណាងរាស្រ្តគណបក្សសង្គ្រោះជាតិពីររូប លោក ញ៉យ ចំរើន និងលោក គង់ សុភា ត្រូវបានអូសចេញពីរថយន្តរបស់ខ្លួននៅក្រៅបរិវេណរដ្ឋសភាជាតិ ហើយត្រូវបានវាយដំយ៉ាងឃោរឃៅដោយជនពាលមួយក្រុម ខណៈដែលមន្រ្តីនគរបាលឈរមើល ហើយពួកគេទាំងពីរនាក់ត្រូវបាន

---

[17] មាស សុខជា 'សកម្មជកគណបក្សសង្គ្រោះជាតិត្រូវបានផ្តន្ទាទោសពីបទ "កុប្បកម្ម" ' *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ http://bit.ly/2dodro5 ។

[18] គណបក្សសម រង្ស៊ី ដែលដឹកនាំដោយលោកសម រង្ស៊ី ជាគណបក្សមួយក្នុងចំណោមគណបក្សពីរដែលបានរួមបញ្ចូលជាគណបក្សសង្គ្រោះជាតិ (ដឹកនាំដោយលោកសម រង្ស៊ីផងដែរ)ក្នុងឆ្នាំ២០១២។ សមាជិកព្រឹទ្ធសភាលោកហុង សុខហួ ត្រូវបានបោះឆ្នោតជ្រើសរើសកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ មុនពេលដែលគណបក្សទាំងពីររួមបញ្ចូលគ្នា ដូចនេះលោកនៅតែតំណាងក្នុងគណបក្សសម រង្ស៊ី។

[19] ឈាង សុខា,'ចាប់ខ្លួនសមាជិកព្រឹទ្ធសភា លោកហុង សុខហួ', *ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥* http://bit.ly/2dXVTCb

[20] មាស សុខជា, ' សមាជិកព្រឹទ្ធសភាគណបក្សសមរង្ស៊ី លោក ហុង សុខហួត្រូវបានចាប់ខ្លួន', *ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៥* http://bit.ly/2dx6nJk។

នាំទៅមន្ទីរពេទ្យព្រមជាមួយនឹងរបួសធ្ងន់ធ្ងរ។[21] ជនដៃដល់បីនាក់ក្នុងចំណោមជនល្មើសជាច្រើន ដែលបម្រើការជាមន្ត្រីឃោជាត្រូវបានចោទប្រកាន់ជុំវិញហេតុការណ៍នោះ[22] ស្របពេលដែលអ្នកឃើញហេតុការណ៍ផ្ទាល់បានកំណត់អត្តសញ្ញាណថាមន្ត្រីនគរបាលដែលស្លៀកពាក់ឯកសណ្ឋានស៊ីវិល និងក្រុមសន្តិសុខជាជនសមគំនិតនៅក្នុងព្រឹត្តិការណ៍វាយដំនោះ[23] ហើយត្រូវបានផ្តន្ទាទោសនៅពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៦ និងត្រូវទទួលទោសជាប់ពន្ធនាគារចំនួន ៤ឆ្នាំ ប៉ុន្តែពួកគេត្រូវបានដោះលែងកាលពីខែវិច្ឆិកា ឆ្នាំ២០១៦។[24]

សកម្មភាពហិង្សាទាំងនេះ កើតឡើងបន្ទាប់ពីមានការតវ៉ាដ៏ធំមួយបានផ្ទុះឡើងនៅខាងក្រៅបរិវេណរដ្ឋសភា ខណៈមានអ្នកតវ៉ាជាងមួយពាន់នាក់បានទាមទារឲ្យទម្លាក់តំណែងលោក កឹម សុខា ដែលជាអនុប្រធានគណបក្សសង្គ្រោះជាតិ ចេញពីអនុប្រធានទីមួយនៃរដ្ឋសភា។[25] នៅថ្ងៃដដែលនោះ មានមនុស្សមួយក្រុមគប់ដុំថ្ម និងដបទឹកចូលទៅក្នុងគេហដ្ឋានរបស់លោកកឹម សុខា អស់រយៈពេលជាច្រើនម៉ោងខណៈដែលប្រពន្ធ របស់លោកលាក់ខ្លួននៅខាងក្នុង ដោយមានការភ័យខ្លាចដល់អាយុជីវិត។[26] នៅពេលដែលមានការហៅទូរស័ព្ទទៅកាន់មន្ត្រីនគរបាលទៅអន្តរាគមន៍ជាបន្ទាន់ នគរបាលទាំងនោះត្រូវបានគេរាយការណ៍ថាបានធ្វើមិនដឹងមិនឮចំពោះការអំពាវនាវទាំងនោះ។[27] បួនថ្ងៃក្រោយមកលោក កឹម សុខា ត្រូវបានដកចេញពីតំណែងជាអនុប្រធានទីមួយរដ្ឋសភាពិតប្រាកដមែន បន្ទាប់ពីមានការបោះឆ្នោតដោយតំណាងរាស្ត្រគណបក្សប្រជាជននៅក្នុងរដ្ឋសភាទាំងអស់ តែការបោះឆ្នោតនេះមានការធ្វើពហិការដោយតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។[28]

បន្ទាប់មកទៀតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ប្រធានគណបក្សសង្គ្រោះជាតិលោក សម រង្ស៊ីត្រូវបានតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនពាក់ព័ន្ធនឹងសំណុំរឿងចាស់ ដែលប្តឹងដោយលោករដ្ឋមន្ត្រីការបរទេស

---

21 https://www.youtube.com/watch?v=NIqa5Mad7Sc.

22 ប៊ុត រស្មីគង្គារ, ខួត សុភក្រ, និងសួន ចំរើន, 'សមាជិកកងយុទ្ធពលខេមរៈភូមិន្ទបីរូបត្រូវបានចោទប្រកាន់បន្ទាប់ពីការវាយដំលើតំណាងរាស្ត្របក្សប្រឆាំង', *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/2egjf5u។

23 សេចក្តីថ្លែងការណ៍រួម៖ អាដហុក, ម.ស.ម.ក, មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, មជ្ឈមណ្ឌលអប់រំច្បាប់ដើម្បីសហគមន៍, សមាគមធាងត្នោត, និងលីកាដូ 'ថ្កោលទោសអំពើហិង្សាលើអ្នកតំណាងរស្ត្រ' រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ http://bit.ly/2eqdqlK។

24 ម៉ិច ដារ៉ា និងសួន ចំរើន, 'ក្រុមអង្គរក្សវាយតំណាងរាស្ត្រត្រូវបានតំឡើងឋានៈ', ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ http://bit.ly/2i8qHED ។

25 យុត សុភចរិយា, ឆាលីស ផាកឃីនសុន និងសួន ចំរើន, 'តំណាងរាស្ត្រត្រូវបានវាយប្រហារនៅរដ្ឋសភាជាតិ' *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៥ http://bit.ly/2eqf86J។

26 សេចក្តីថ្លែងការណ៍រួម៖ អាដហុក, ម.ស.ម.ក, មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, មជ្ឈមណ្ឌលអប់រំច្បាប់ដើម្បីសហគមន៍, សមាគមធាងត្នោត, និងលីកាដូ 'ថ្កោលទោសអំពើហិង្សាលើអ្នកតំណាងរាស្ត្រ' រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ។

27 មាស សុខជា ឆាយ ចាន់នីតា និងឆាលីស ផាកឃីនសុន , ' ពិភពលោកកំពុងតាមដាន' ការស៊ើបអង្កេត *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៥ http://bit.ly/2e3Vwtd។

28 សួន ចំរើន និងឆាយ ចាន់ធីតា, ' លោក កឹម សុខា ត្រូវបានដកចេញពីតំណែងអនុប្រធានទី១រដ្ឋសភា', *ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៥* http://bit.ly/2edwlmh ។

ហោ ណាំងហុង កាលពីឆ្នាំ២០០៨។[29] ដីការបង្គាប់ឲ្យចាប់ខ្លួននេះ បណ្តាលមកពីសង្គ្រាមពាក្យសម្តីកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅពេលដែលលោកនាយករដ្ឋមន្ត្រីហ៊ុន សែនហៅលោក សម រង្ស៊ីថាជា "កូនអាក្បត់ជាតិ" [30] ដោយសំដៅទៅឪពុករបស់លោក គឺលោក សម សារី ជាអតីតរដ្ឋមន្ត្រីនៅសម័យសម្តេច នរោត្តម សីហនុ។[31] បីថ្ងៃក្រោយមកលោក សម រង្ស៊ីដែលពេលនោះកំពុងនៅបរទេស ក៏សម្រេចចិត្តស្នាក់នៅបរទេសបន្តបន្ទាប់ពីការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ហើយតួនាទីជាសមាជិកសភា រួមទាំងអភ័យឯកសិទ្ធិសភារបស់គាត់ត្រូវបានដកហូតផងដែរ។[32]

នៅសប្តាហ៍ដដែលនេះ គឺថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ លោក សម រង្ស៊ី ដែលបច្ចុប្បន្នកំពុងតែប្រឈមនឹងការរិះគន់ ត្រូវបានតុលាការចោទប្រកាន់ពីបទចោទថ្មីជាបណ្តោះអាសន្នថែមទៀត ថាជាអ្នកសមគំនិតនៅក្នុងបទល្មើសក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារក្លែងក្លាយ និងញុះញង់ឲ្យមានចលាចលធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងសំណុំរឿងខាងលើរបស់លោកហុង សុខហួរ។[33] បន្ទាប់មក នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាបន្ថែមទៀត ដែលតំណាងឲ្យប្រធានរដ្ឋសភា លោក ហេង សំរិន ដែលបង្គាប់ឲ្យលោកសម រង្ស៊ី បញ្ជាក់អំពីការផ្សព្វផ្សាយមានលក្ខណៈនយោបាយនៅក្នុងអត្ថបទហ្វេសប៊ុកដែលលោកបានសរសេរនៅក្នុងខែវិច្ឆិកា និងតម្រូវឲ្យចូលខ្លួនឆ្លើយបំភ្លឺលើបទបរិហារកេរ្តិ៍ថ្មីនេះ។.[34]

ឆ្នាំ២០១៦ បង្ហាញឲ្យឃើញនូវការគាបសង្កត់តាមផ្លូវតុលាការ និងហិង្សាប្រឆាំងនឹងគណបក្សប្រឆាំងស្រដៀងៗគ្នាដែរ។ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ មានការចេញដីកាថ្មីមួយទៀត ប្តឹងលោកសម រង្ស៊ីពីបទល្មើសមួយផ្សេងទៀត លើកនេះបណ្តឹងធ្វើឡើងដោយលោក សោម សឿន រដ្ឋមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជា ដែលកាលពីដើមខែនោះ លោកសម រង្ស៊ីបានចោទលោក សោម សឿនថាពាក់ព័ន្ធនឹងផែនការជួលជនក្រីក្រនៅប្រទេសឥណ្ឌា និងហ្វីលីពីនឲ្យចុច "like" ទំព័រហ្វេសប៊ុកលោកនាយករដ្ឋមន្ត្រីហ៊ុន សែនដើម្បីបង្កើន

[29] ភ័ក្រ្ត សៀងលី និងសួន ច័រតុន, 'តុលាការចេញដីការចាប់ខ្លួនលោក សម រង្ស៊ី' , *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/2dKXmKp ។

[30] វង្ស សុខឃេង, 'នាយករដ្ឋមន្ត្រីវាយប្រហារឿងបុគ្គលលើលោក សម រង្ស៊ី ' , *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/2dxbRnb ។

[31] ចូ ហ្វ្រីមែន , 'ជីវិតជាអ្នកនយោបាយប្រឆាំង' (សេចក្តីសង្ខេបសៀវភៅ) *Asia Times Online* ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ http://bit.ly/2egk9Py។

[32] ឆាយ ចាន់នីតា និងទៀង វីដា, 'លោក សម រង្ស៊ី បាត់បង់អភ័យឯកសិទ្ធិសភា', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/2eMf7wZ។

[33] ភ័ក្រ សៀងលី និងស្ទួអាថ វ៉ៃធ៍, 'តុលាការចេញដីការកោះហៅលោក សម រង្ស៊ីជាថ្មី', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ http://bit.ly/2dxcey5។

[34] វុទ្ធី ថា បញ្ញាវឌ្ឍ និងចូស្ទូ លីផែស , 'តុលាការកម្ពុជាកោះហៅលោកសម រង្ស៊ី ក្នុងបទបរិហារកេរ្តិ៍ថ្មី', វិទ្យុអាស៊ីសេរី ថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៥ http://bit.ly/2dKWjKn។

ប្រជាប្រិយភាពនៅលើបណ្តាញសង្គម។[35] នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ លោក សម រង្ស៊ីត្រូវបានតុលាការផ្តន្ទាទោសពីបទនេះ និងតម្រូវឲ្យបង់ប្រាក់ពិន័យ ២.៥០០ ដុល្លារអាមេរិក និង៣.៧៥០ ដុល្លារអាមេរិកសម្រាប់សំណងជំងឺចិត្ត។[36]

យ៉ាងណាក្តីមុននេះ លោកសម រង្ស៊ីត្រូវបានកាត់ទោសពីបទបរិហារកេរ្តិ៍ដែលប្តឹងដោយ លោក ហេង សំរិន កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ហើយត្រូវពិន័យឲ្យបង់ប្រាក់ ៣៧.៥០០ ដុល្លារអាមេរិកជាសំណងជំងឺចិត្ត។[37] កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្តឹងលោក សម រង្ស៊ី ពីបទបរិហារកេរ្តិ៍ ព្រមទាំងប្តឹងសមាជិកព្រឹទ្ធសភាគណបក្សសម រង្ស៊ី លោកស្រី ថាក់ ឡានី ដែលត្រូវបានកាត់ទោសកាលពីពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១៦[38] លើករណីដែលលោកស្រី ថាក់ ឡានី បានចោទថារដ្ឋាភិបាលនៅពីក្រោយការបាញ់សម្លាប់លោក កែម ឡី អ្នកវិភាគនយោបាយកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦។[39] អាជ្ញាធរបានចោទប្រកាន់ជនឈ្មោះ អឿត អាង ជាអតីតមន្ត្រីទាហានពីបទមនុស្សឃាតដោយគិតទុកជាមុនមកលើលោក កែម ឡី ដែលជាអ្នកធ្លាប់បានរិះគន់រដ្ឋាភិបាលមិនសំចៃមាត់ ហើយដោយលើកហេតុផលដែលឈានដល់ឃាតកម្មនេះថាដោយសារលោកកែម ឡី ជំពាក់លុយខ្លួន ៣.០០០ ដុល្លារអាមេរិក យ៉ាងណាក្តីហេតុផលមួយនេះ រងការរិះគន់យ៉ាងខ្លាំងពីសាធារណជន[40]។ នៅពេលដែលឆ្នាំ២០១៦ ជិតនឹងបញ្ចប់កាលថ្ងៃទី២៧ ខែធ្នូ លោក សម រង្ស៊ី និងសហការីពីររូបទៀត ដែលជាអ្នកកាន់ទំព័រហ្វេសប៊ុករបស់លោកត្រូវបានកាត់ទោសឲ្យជាប់ពន្ធធនាគារម្នាក់ៗ ចំនួន ៥ឆ្នាំ ពីបទបង្ហោះវីដេអូរបស់លោកហុង សុខហួរ ដែលបានបញ្ជាក់ខាងលើ។[41]

ទន្ទឹមនឹងនេះដែរ អនុប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា បានស្ថិតនៅក្រោមការវាយប្រហារជាថ្មីឡើងវិញនៅពេញមួយ ឆ្នាំ២០១៦ ដោយចាប់ផ្តើមពីការចេញខ្សែអាត់សំឡេងកាលពីដើមខែមីនា

---

[35] គួច ណារ៉ែន, 'លោក សម រង្ស៊ីត្រូវបានកោះហៅឲ្យទៅតុលាការលើបណ្តឹងហ្វេសប៊ុក', ខេមបូឌាដេលី ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៦ http://bit.ly/2ePxvVu ។

[36] វុទ្ធី ហួត, 'តុលាការកម្ពុជារកឃើញថាមេដឹកនាំគណបក្សប្រឆាំងមានទោសពីបទបរិហារកេរ្តិ៍', វិទ្យុអាស៊ីសេរី ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ http://bit.ly/2j2qHpo។

[37] នៀប ឆេង និងអាណាត បាលីហ្គា, 'លោក សម រង្ស៊ីត្រូវបានតុលាការចេញសាលក្រមថាមានពិរុទ្ធពីបទបរិហារកេរ្តិ៍លោកហេង សំរិន', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ http://bit.ly/2ibdIgA។

[38] នៀប ឆេង និងសួន ច័រតុន, 'ផ្តន្ទាទោសសមាជិកព្រឹទ្ធសភាដាក់គុកមួយឆ្នាំកន្លះ', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ http://bit.ly/2iYDadh។

[39] ចានដារា យាង និងថា ថៃ, 'រឿងចោទសម្លាប់លោកកែម ឡីធ្វើឲ្យលោកនាយករដ្ឋមន្ត្រីហ៊ុន សែនដោះស្រាយតាមផ្លូវតុលាការ' *វិទ្យុអាស៊ីសេរី* ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ http://bit.ly/2egj2A2។

[40] ប្រភពដូចខាងលើ។

[41] ឡាយ សាមាន និងអ៊ីរិន ហៃនឡេ, 'លោក សម រង្ស៊ី និងសហការី ២ រូបត្រូវជាប់គុកក្នុងម្នាក់ៗ ៥ ឆ្នាំ', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ http://bit.ly/2iyYVxd។

ដែលត្រូវបានសង្ស័យថាជាសំឡេងលោក កឹម សុខានិយាយជាមួយនឹងស្រីកំណាន់។[42] សំឡេងមនុស្សស្រីនៅក្នុងខ្សែអាត់ត្រូវបានបញ្ជាក់ជាបឋមថាជាសំឡេងរបស់ ខុម ចាន់ដារ៉ាទី ជាជាងអ៊ិតសក់ ដែលដើមឡើយនាងបានបដិសេធការចោទប្រកាន់ថានាងធ្លាប់មានទំនាក់ទំនងស្នេហាជាមួយលោកកឹម សុខា និងបានរកជំនួយពីបុគ្គលិកអង្គការអាដហុក។[43] យ៉ាងណាក្តី នៅថ្ងៃទី២០ ខែមេសា ខុម ចាន់ដារ៉ាទីបានប្តូរសាច់រឿងរបស់ខ្លួន និងទទួលស្គាល់ថានាងជាស្រីកំណាន់របស់លោកកឹម សុខា[44] ហើយប៉ុន្មានថ្ងៃក្រោយមក បានបង្វែរឿងទៅមេធាវីរបស់នាង និងបានចោទពួកគេថាបានយកលុយសូកនាងឲ្យបដិសេធរឿងមានទំនាក់ទំនងស្នេហា។[45] នៅថ្ងៃទី២ ខែឧសភា បុគ្គលិកអង្គការអាដហុកបួននាក់ និងអតីតបុគ្គលិកអាដហុកម្នាក់ លោក នី ចរិយាដែលបច្ចុប្បន្នជាអគ្គលេខាធិការរង គ.ជ.ប រួមទាំងបុគ្គលិកម្នាក់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ត្រូវបានចោទប្រកាន់ និងមួយថ្ងៃក្រោយមកត្រូវបានបញ្ជូនទៅពន្ធធនាគារព្រៃស (លើកលែងតែបុគ្គលិករបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលមានអភ័យឯកសិទ្ធិជាមន្ត្រីរបស់អង្គការសហប្រជាជាតិ គេចផុតពីការកាត់ទោស)។[46]

កាលពីដើមខែកញ្ញា លោក កឹម សុខា ត្រូវបានកាត់ទោសដោយកំបាំងមុខ ឲ្យជាប់ពន្ធធនាគារ ៥ខែ ពីបទបដិសេធក្នុងការចូលខ្លួនតាមការកោះហៅរបស់តុលាការ។[47] រហូតដល់ដើមខែធ្នូ ឆ្នាំ២០១៦ លោក កឹម សុខា បានលាក់ខ្លួននៅក្នុងទីស្នាក់ការគណបក្សសង្គ្រោះជាតិ ដោយបានចេញមកខាងក្រៅប្រមាណជាពីរបីម៉ោងនៅក្នុងខែតុលា ដើម្បីចុះឈ្មោះបោះឆ្នោត ជាមួយនឹងភាពភ័យខ្លាចពីការចាប់ខ្លួន និងអំពើហិង្សាដែលនឹងអាចកើតឡើង។[48] បើទោះបីជាសាលាឧទ្ធរណ៍បានសម្រេចបដិសេធនូវបណ្តឹងរបស់មេធាវីលោកកឹម សុខា ដើម្បីស្នើសុំឲ្យទម្លាក់ចោលការចោទប្រកាន់[49] ក៏ដោយ លោក កឹម សុខាត្រូវបានព្រះមហាក្សត្រប្រទានការលើកលែង

---

[42] ប៊ុន សេងហុង, 'ខ្សែអាត់សំឡេងបានផ្តល់តម្រុយនៃភាពមិនស្មោះត្រង់របស់អនុប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា' *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៦ http://bit.ly/2eW0O8I ។

[43] នៀប ឆេង, 'ស្រីមុំបដិសេធទំនាក់ទំនងស្នេហាជាមួយលោកកឹម សុខា' *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ http://bit.ly/2fjaEmj។

[44] ឡាយ សាមាន, 'ស្រីកំណាន់លោកកឹម សុខា ប្តូររឿងនៅក្នុងតុលាការ', *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ http://bit.ly/2dSiTov។

[45] ឡាយ សាមាន និងស្ហួន ច័រតុន, 'ស្រីកំណាន់ប្តឹងលោក កឹម សុខា និងបុគ្គលិកអាដហុក', *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៦ http://bit.ly/2e0ehI1 ។

[46] ឡាយ សាមាន និង អាណាត បាលីហ្គា, ' អ្នកធ្វើការសិទ្ធិមនុស្ស,ពីរនាក់ផ្សេងទៀត និងមន្ត្រីអង្គការសហប្រជាជាតិត្រូវតុលាការចោទប្រកាន់ពីបទ "សូកប៉ាន់សាក្សី" ' *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី៣ ខែ ឧសភា ឆ្នាំ២០១៦ http://bit.ly/2f57ZIe ។

[47] ប្រូក បូលៀក, 'តុលាការកម្ពុជាកាត់ទោសលោក កឹម សុខាដាក់ពន្ធធនាគារ៥ខែ' *វិទ្យុអាស៊ីសេរី* ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ http://bit.ly/2dSlJtq។

[48] មៀច ដារ៉ា និងអាលិច វ៉ិលៀមមីន, 'កឹម សុខា ចេញពីទីស្នាក់ការគណបក្សទៅចុះឈ្មោះបោះឆ្នោតបានបង្កើនក្តីសង្ឃឹម', *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០១៦ http://bit.ly/2f1LmWb ។

[49] នៀប ឆេង, 'បណ្តឹងឧទ្ធរណ៍របស់លោកកឹម សុខាបានបរាជ័យ', *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៦ http://bit.ly/2fvYnGt ។

ទោស តាមសំណើររបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៦ ដែលអនុញ្ញាតឲ្យរួចទោសពីបទបដិសេធក្នុងការចូលខ្លួនតាមការកោះហៅរបស់តុលាការ។[50]

ចុងក្រោយ ករណីថ្មីបំផុតនោះគឺតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិលោក អ៊ុំ សំអាង ត្រូវបានកាត់ទោសដាក់ពន្ធធនាគាររយៈពេលពីរឆ្នាំកន្លះកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ក្នុងករណីដែលលោកបានបង្ហោះសាររិះគន់រដ្ឋាភិបាលលើហ្វេសប៊ុក ដោយចោទថាប្រើប្រាស់ផែនទីក្លែងក្លាយ បោះបង្គោលព្រំដែនជាមួយវៀតណាម ដែលធ្វើឲ្យខ្មែរបាត់បង់ទឹកដីទៅខាងវៀតណាម។[51] លោក អ៊ុំ សំអាន ត្រូវបានចោទប្រកាន់នៅក្នុងខែមេសា ឆ្នាំ២០១៦ បើទោះបីជាការបង្ហោះសារត្រូវបានធ្វើឡើងកាលពីឆ្នាំមុនក៏ដោយ បង្កឲ្យមានការព្រួយបារម្ភបន្ថែមទៀត ថារឿងក្ដីនេះត្រូវបានធ្វើឡើងក្នុងគោលបំណងនយោបាយ។

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ទីស្ដីការគណៈរដ្ឋមន្ត្រីបានចេញលិខិតណែនាំហាមឃាត់មិនឲ្យក្រុមហ៊ុនអាកាសចរណ៍ទាំងអស់លក់សំបុត្រឲ្យលោក សម រង្ស៊ី ដែលបាននិរទេសខ្លួននៅក្រៅប្រទេសតាំងពីការកាត់ទោសលើកទីមួយធ្វើឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០១៥ ឲ្យវិលត្រលប់ចូលកម្ពុជាវិញនោះទេ និងព្រមានថាយន្តហោះណាមួយដែលដឹកលោក សម រង្ស៊ី យន្តហោះនោះនឹងត្រូវបង្វែរឲ្យវិលត្រលប់ទៅកាន់អាកាសយានដ្ឋានដើមវិញ លិខិតនោះក៏បានហាមឃាត់មិនឲ្យលោក សម រង្ស៊ី ចូលស្រុកវិញតាមវិធីសាស្ត្រណាមួយផងដែរ រួមទាំងហាមមិនឲ្យនគរបាលអន្តោប្រវេសន៍ អនុញ្ញាតិឲ្យបុគ្គលនេះចូលកម្ពុជាវិញ។[52]

## ៤. យុទ្ធសាស្ត្រនយោបាយ

នៅក្រសែភ្នែកអ្នកសង្កេតនយោបាយ នយោបាយនៅកម្ពុជា និងយុទ្ធសាស្ត្រដែលប្រើដោយគណបក្សនយោបាយធំៗ ជារឿយៗមានលក្ខណៈមិនសមហេតុផល និងផ្ទុយទៅនឹងគោលបំណងរបស់គណបក្ស។ ថ្វីបើមានការពិតមួយចំនួនពាក់ព័ន្ធនឹងទស្សនៈបែបនេះក៏ដោយ តែយុទ្ធសាស្ត្រដែលគណបក្សនយោបាយបានប្រើប្រាស់ គឺតាមពិតទៅ និងភាគច្រើនទៅ មានការពិចារណាបានដិតដល់ និងយ៉ាងផ្ចិតផ្ចង់។ ផ្នែកបន្ទាប់នៃអត្ថបទនេះនឹងផ្ដល់សេចក្ដីសង្ខេបស្ដីពីយុទ្ធសាស្ត្រដែលប្រើដោយគណបក្សនយោបាយធំៗទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

---

[50] មៀច ដារ៉ា, 'ព្រះមហាក្សត្រប្រទានការលើកលែងទោសលោក កឹម សុខា', *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៦, http://bit.ly/2jo5pyW។

[51] នៀប ឆេង, 'កាត់ទោសលោក អ៊ុំ សំអានដាក់ពន្ធធនាគារ' , *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ http://bit.ly/2eigVi4។

[52] ទូច សុខា, 'លោកសម រង្ស៊ីថាជាការនិរទេសខ្លួនពិតប្រាកដ', *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ http://bit.ly/2dBIXiD ។

## គណបក្សប្រជាជនកម្ពុជា

ការបោះឆ្នោតជាតិឆ្នាំ២០១៣ ជារបត់នៃការផ្លាស់ប្តូរមួយ។ បើទោះបីជាមានភាពមិនប្រក្រតីកើតឡើងគួរឲ្យកត់សម្គាល់ និងយុទ្ធនាការបោះឆ្នោតនៅតាមមូលដ្ឋានដែលមិនមានលក្ខណៈស្មើភាពគ្នាយ៉ាងណាក្តី[53] គណបក្សសង្គ្រោះជាតិបានបង្កបញ្ហាជាខ្លាំងដល់គណបក្សប្រជាជន ដែលដំបូងឡើយគឺនៅតាមមណ្ឌលបោះឆ្នោត និងបន្ទាប់មកទៀតគឺនៅតាមដងវិថីក្នុងរាជធានីភ្នំពេញ។ គណបក្សប្រជាជនមិនអាចថាមិនព្រួយបារម្ភទៀតនោះទេ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ ២០១៣មក គណបក្សប្រជាជនទំនងដូចជាប្រឈមនឹងដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់ និងមានភាពស៊ីសង្វាក់ ដើម្បីអាចទប់ទល់ជាមួយនឹងកត្តាផ្សេងៗ បញ្ហាប្រឈម ការគំរាមកំហែង និងរលកនៃការផ្លាស់ប្តូរដែលជះឥទ្ធិពលមកលើនយោបាយកម្ពុជាចាប់តាំងពីការបោះឆ្នោតជាតិឆ្នាំ២០១៣។

ដើមឡើយ ភ្លាមៗបន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០១៣ យុទ្ធសាស្ត្ររបស់គណបក្សប្រជាជន គឺត្រូវធ្វើយ៉ាងណាដើម្បីគ្រប់គ្រងស្ថានការណ៍ឡើងវិញ តាមរយៈការធ្វើឲ្យគណក្សសង្គ្រោះជាតិចុះខ្សោយ និងបង្ខំឲ្យបាតុករចាកចេញពីដងវិថីនានានៅរាជធានីភ្នំពេញ ឲ្យបានឆាប់តាមដែលអាចធ្វើបាន នៅខណៈដែលត្រូវប្រើប្រាស់កម្លាំង និងការបង្ហូរឈាមកាន់តែតិចតាមដែលអាចធ្វើបាន។ បន្ទាប់ពីគ្រប់គ្រងស្ថានការណ៍បានពេញលេញវិញនៅក្នុងខែមករា ឆ្នាំ២០១៤ គណបក្សប្រជាជនអាចចាប់ផ្តើមចរចាជាមួយគណបក្សប្រឆាំងដែលស្ថិតក្នុងសភាពទន់ខ្សោយ និងពុំសូវមានឥទ្ធិពលដូចមុន។ ការផ្លាស់ប្តូរនេះមិនត្រឹមតែលើកមុខមាត់របស់របស់គណបក្សប្រជាជន នៅក្នុងក្រសែភ្នែករបស់ប្រជាជនបន្ទាប់ពីការបាញ់ប្រហារនៅក្នុងខែមករា ឆ្នាំ២០១៤ ប៉ុណ្ណោះទេ តែថែមទាំងបានធ្វើឲ្យគណបក្សប្រឆាំងលែងសូវមានប្រសិទ្ធភាពទៀតផង។ អាយុកាលនៃយុទ្ធសាស្ត្រនេះមិនវែងប៉ុន្មានទេ នៅពាក់កណ្តាលឆ្នាំ២០១៥ គណបក្សកាន់អំណាចវិលត្រលប់មកប្រើប្រាស់ល្បិចចាស់។ ជាជាងបន្តជម្រើសដែលមានការវិវឌ្ឍ ដែលបានគូសវាសក្នុងឆ្នាំ២០១៤ គណបក្សប្រជាជនបានពង្រឹងអំណាចរបស់ខ្លួនឡើងវិញ និងត្រលប់ទៅប្រើយុទ្ធសាស្ត្រសាកល្បង និងប្រមូលទំនុកចិត្ត។

បើទោះបីជា យុទ្ធសាស្ត្ររបស់គណបក្សប្រជាជន ដែលធ្វើគណបក្សប្រឆាំងចុះខ្សោយតាមរយៈផ្លូវតុលាការ យុទ្ធសាស្ត្រនេះអមដោយយុទ្ធសាស្ត្រផ្សេងៗទៀតក្នុងគោលបំណងដូចគ្នាដែរដើម្បីឲ្យឥទ្ធិពលគណបក្សប្រឆាំងចុះខ្សោយទូទាំងប្រទេស។ ឧទាហរណ៍ គណបក្សប្រជាជនស្វាគមន៍ជានិច្ចនូវគណបក្សថ្មីដែលអាចបំបែកសំឡេង វាយប្រហារ ឬធ្វើឲ្យគណបក្សសង្គ្រោះជាតិបាត់បង់ប្រជាប្រិយភាព។[54] សូម្បីតែគណបក្សនយោបាយដែលមានឯករាជ្យភាពពិតប្រាកដក៏ត្រូវបានស្វាគមន៍នៅលើឆាកនយោបាយនេះដែរ បើតាមអ្វីដែល

---

[53] គណកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល), 'លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា', (របាយការណ៍ប្រចាំឆ្នាំ២០១៣) ភ្នំពេញ ខែមេសា ឆ្នាំ២០១៤ , ទំព័រ ១៨ ដល់ ២២, http://bit.ly/2e1To2Z។

[54] ឌិន ភាព, 'អតីតតំណាងរាស្ត្រមកពីគណបក្សប្រជាជនប្រកាសពីគម្រោងបង្កើតគណបក្សនយោបាយថ្មី' ខេមបូឌាដេលី ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/former-cpp-lawmaker-announces-plans-to-form-new-party-101299/.

គណបក្សប្រជាជនយល់ឃើញ។[55] យុទ្ធសាស្ត្រនេះកំពុងតែទាក់ទាញចំណាប់អារម្មណ៍ប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស ជាពិសេសនៅសហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលី។

គណបក្សប្រជាជនក៏ព្យាយាមប្រមូលសន្លឹកឆ្នោតឡើងវិញ តាមរយៈការខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមបន្ទាន់មួយចំនួនរបស់ជាតិ កំណែទម្រង់មួយចំនួនដែលបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ផ្អែកលើការសម្រេចចិត្តនៃគោលនយោបាយយ៉ាងពិតប្រាកដ។ ទន្ទឹមនឹងនេះ គណបក្សប្រជាជនបានផ្តោតការយកចិត្តទុកដាក់លើការទាក់ទាញការគាំទ្រពីយុវជន ដែលជាមូលដ្ឋានគ្រឹះរបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំ២០១៣។ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន នាពេលថ្មីៗនេះបានងាកមកចាប់អារម្មណ៍បណ្តាញសង្គមហ្វេសប៊ុក[56] ដែលលោកអាចបង្ហាញនូវភាពជិតស្និទជាងមុន ដោយមានរូបភាពជា "បុគ្គលសាមញ្ញ" ទៅកាន់សាធារណៈជន ព្រមទាំងបង្ហាញការគាំទ្រកូនប្រុសពៅរបស់គាត់គឺលោក ហ៊ុន ម៉ានី ជាតួអង្គថ្មីរបស់គណបក្សប្រជាជន។ អស់រយៈពេលជាងពីរឆ្នាំមកហើយ ដែលលោក ហ៊ុន ម៉ានី ក្នុងនាមជាប្រធានសហភាពសហព័ន្ធប្រជាជនកម្ពុជា បានចូលរួមយ៉ាងផុសផុលជាមួយអ្នកលេងហ្វេសប៊ុក និងយុវជនដើម្បីផ្ញើសារសំខាន់ៗរបស់គណបក្សប្រជាជនក្នុងន័យឃោគយល់គ្នា និងស្តាប់ការព្រួយបារម្ភ ព្រមទាំងទទួលយកគំនិតរបស់ក្រុមទាំងនោះ។[57]

ស្របគ្នានេះដែរ គណបក្សប្រជាជនបានបង្កើនការគ្រាំទ្រពីចិនមកលើគណបក្សខ្លួនជាសន្សឹមៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ដោយចិនបានចំណាយរាប់លានក្នុងមួយឆ្នាំៗ ផ្តល់ជំនួយដោយផ្ទាល់ដល់រដ្ឋាភិបាល។ ក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាអំឡុងខែតុលា ឆ្នាំ២០១៦ របស់នាយករដ្ឋមន្ត្រីចិន លោកស៊ី ជិនពីង មានកិច្ចព្រមព្រៀងចំនួន៣១ ដែលប្រទេសទាំងពីរបានចុះហត្ថលេខា រួមទាំងការលុបបំណុលប្រមាណជា ៩០ លានដុល្លារអាមេរិក និងផ្តល់ជំនួយយោធាចំនួន ១៥ លានដុល្លារអាមរិក។[58] នៅពេលដែលជំនួយផ្នែកសេដ្ឋកិច្ច និងនយោបាយរបស់ចិនមកលើកម្ពុជាកាន់តែកើនឡើង ការផ្តាប់ចិត្តម្ចាស់ជំនួយអន្តរជាតិផ្សេងទៀតតាមរយៈកំណែទម្រង់កាន់តែមិនចាំបាច់សម្រាប់កម្ពុជា។

គណបក្សប្រជាជន ត្រូវយល់ថាអ្វីៗបានផ្លាស់ប្តូរហើយ ចាប់តាំងពីការបោះឆ្នោតជាតិ ឆ្នាំ២០១៣។ គណបក្សប្រជាជនកម្ពុជាត្រូវទទួលស្គាល់ថាអាចនឹងមានចលនាយុជនតាមបែបលទ្ធិប្រជាធិបតេយ្យ ដែលប្រមូលផ្តុំជាកម្លាំងដ៏មហាសាល ហើយមិនយូរមិនឆាប់អាចនឹងមានការទាមទារ និងសម្រេចឲ្យបាននូវការផ្លាស់

---

[55] ដេវីត ហាត់ , `តួអង្គទាំងបួន៖ គណបក្សនយោបាយថ្មីនៅកម្ពុជា´, *Southeast Asia Globe* ,ថ្ងៃទី១ ខែ តុលា ឆ្នាំ២០១៥ http://bit.ly/2dC8NGj

[56] https://www.facebook.com/hun. sencambodia/?fref=ts.

[57] ខេវីន ផូណែ, `លោក ហ៊ុន ម៉ានី បើកចំហទទួលមតិរិះគន់´ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ http://bit.ly/2eC4wCi។.

[58] សុផេង ឈាង/AP , `ចិនលុបបំណុលដែលកម្ពុជាជំពាក់៩០លានដុល្លាអាមេរិក´ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ , *The Washington Post*, http://wapo.st/2f7wdTA។

ប្តូរ។ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ "ប្រចាំត្រកូល" នោះ គណបក្សប្រជាជននឹងប្រឈមនឹងហានិភ័យ ក្នុងការងាកចេញពីសេចក្តីត្រូវការ បំណងប្រាថ្នា និងចក្ខុវិស័យរបស់ប្រជាពលរដ្ឋខ្មែរ។

## គណបក្សសង្គ្រោះជាតិ

លោក សម រង្ស៊ី ដែលជ្រកក្រោមស្លាកគណបក្សសម រង្ស៊ី តែងតែប្រើប្រាស់វោហាស័ព្ទបែបប្រជានិយមដើម្បីគាំទ្រពីថ្នាក់មូលដ្ឋានរបស់ខ្លួន។ ស្រដៀងគ្នានេះដែរ លោក កឹម សុខា ទទួលបានប្រជាប្រិយភាពខ្លាំងក្លាផងដែរ ដោយសារតែការបញ្ចេញមតិទាក់ទងនឹងបញ្ហាជនជាតិវៀតណាម។ ភ្លាមៗបន្ទាប់ពីបង្រួមគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សជាគណបក្សតែមួយ គណបក្សថ្មីមួយនេះ នៅតែដើរតាមគន្លងដែលគណបក្សសម រង្ស៊ី បានកំណត់រួចហើយ និងមេដឹកនាំរបស់គណបក្សបន្តរយកកំហឹងប្រវត្តិសាស្ត្រដែលមានលើប្រទេសវៀតណាម និងជនជាតិភាគតិចវៀតណាមនៅក្នុងប្រទេសកម្ពុជា ជាយុទ្ធសាស្ត្រចម្បងមួយរបស់គណបក្ស។[59] ដោយការធ្វើដូច្នេះ គណបក្សសង្គ្រោះជាតិកំពុងអុចស្នាមរបួសនយោបាយ ប្រវត្តិសាស្ត្រ ភាពស្មុកស្មាញដែលដក់ជាប់ក្នុងអារម្មណ៍ និងផ្នែកចិត្តសាស្ត្រ។ មេដឹកនាំគណបក្សសង្គ្រោះជាតិ បន្តព្យាយាមធ្វើឲ្យគណបក្សប្រជាជនកម្ពុជាចុះខ្សោយតាមរយៈការប្រើប្រាស់វោហាស័ព្ទ ដែលមានលក្ខណៈបំផុសបំផុលផ្នែកនយោបាយ និងរើសអើងជាតិសាសន៍។[60] មេបក្សប្រឆាំង សង្កត់ហើយសង្កត់ទៀតទៅលើទំនាក់ទំនងរបស់គណបក្សប្រជាជនទៅនឹងរបបខ្មៅងងឹតខ្មែរក្រហមនាទសវត្សរ៍ទី៧០ និងប្រទេសវៀតណាម។[61]

អ្វីដែលមិនគួរឲ្យរីករាយនោះ គឺវោហាស័ព្ទប្រឆាំងនឹងវៀតណាមរបស់គណបក្សសង្គ្រោះជាតិ បែរជាទទួលជោគជ័យយ៉ាងខ្លាំងជាមួយនឹងអ្នកគាំទ្រជាច្រើន។ ប៉ុន្តែ ក៏មិនមែនមានន័យថាគ្មានហានិភ័យអ្វីនោះដែរ។ លើសពីនេះទៀត ប្រជាជនវៀតណាម និងអាជីវកម្មរបស់ពួកគេ ឬពេលខ្លះមានការសង្ស័យថាជារបស់វៀតណាម ត្រូវបានទុកជាគោលដៅក្នុងអំឡុងពេលបាតុកម្ម។ អំឡុងដើមខែមករា ឆ្នាំ ២០១៤ បាតុកម្មនៅវិថីវេងស្រេងត្រូវបានអ្នកតាមដានស្ថានការណ៍ និងអ្នកកាសែតកត់ចំណាំថា បាតុករបានស្រែករើសអើងជនជាតិ ហើយពួកគេបានលួច និងវាយបំផ្លាញអាជីវកម្មរបស់ជនជាតិវៀតណាមតាមដងផ្លូវ។[62]

យុទ្ធសាស្ត្រចម្បងមួយទៀតរបស់គណបក្សសង្គ្រោះជាតិ បានលេចឡើងដើម្បីបង្កើតម្តងទៀតនូវព្រឹត្តិការណ៍ឆ្នាំ២០១៣ ឲ្យកាន់តែធំ និងប្រសើរជាងមុន។ លើសពីនេះទៀត លោក សម រង្ស៊ី កំពុងទុកចិត្ត

---

59 ខេវិន ផូណៃ, 'ការប្រឆាំងនឹងវៀតណាមរបស់គណបក្សសង្គ្រោះជាតិ "ពញ៉ាក់អារម្មណ៍" ដល់ប្រេសិតពិសេស' ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤http://bit.ly/2emTHmx ។

60 ពិតទ័រ តាន់ កែវ, 'អំពើហិង្សាបណ្តាលឲ្យមានហិង្សានៅកម្ពុជា', *Asia Times Online* ថ្ងៃទី១៧ មករា ឆ្នាំ២០១៤, http://bit.ly/2emc6Eo។

61 ប្រភពដូចខាងលើ។

62 ជូលា វ៉ាល់ឡាស់ និងនូ វ៉ណ្ណារិន, 'កម្ពុជាតវ៉ាបង្ហាញពីទស្សនៈប្រឆាំងវៀតណាម', *Al Jazeera*, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ http://bit.ly/2ePbger។

ដោយភាពឆោតល្ងង់ ទៅលើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយធ្វើទង្វើដដែលចាប់ពីឆ្នាំ ២០១៣ ក្នុងការស្នើសុំព្រះរាជក្រឹត្យលើកលែងទោស។ ដោយផ្តល់លទ្ធផលដូចការបោះឆ្នោតឆ្នាំ ២០១៣ ក្រោយការវិវឌ្ឍនោះ វាគឺជារឿងគួរភ្ញាក់ផ្អើលប្រសិនបើលោក ហ៊ុន សែន នៅបន្តធ្វើរឿងដដែល។

នៅក្នុងប្រទេសដែលមានការកើនឡើងនូវចំនួនប្រជាជនដែលប្រើប្រាស់អ៊ីនធើណេត និងភ្ជាប់ជាមួយនឹងបណ្តាញសង្គម ការប្រើប្រាស់ឧបករណ៍ទាំងនេះដើម្បីនាំឲ្យការគាំទ្រមានភាពសកម្មឡើងវិញនោះ គឺកាន់តែសំខាន់ឡើងៗ ហើយគណបក្សសង្គ្រោះជាតិ តាំងពីពេលចាប់ផ្តើមរហូតមកដល់បច្ចុប្បន្ន បានឆ្លៀតឱកាសយកចំណេញលើរឿងនេះ។ ចាប់ផ្តើមដោយមហាបាតុកម្មនៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ មេដឹកនាំគណបក្សសង្គ្រោះជាតិ បានប្រើប្រាស់បណ្តាញសង្គមដើម្បីមូលផ្តុំមូលដ្ឋានគាំទ្ររបស់ខ្លួន និងដើម្បីផ្សារភ្ជាប់ទៅក្រុមអ្នកបោះឆ្នោតថ្មី គឺយុវជនខ្មែរ។

លើសពីនេះទៅទៀត ចាប់តាំងពីការបោះឆ្នោតជាតិឆ្នាំ ២០១៣ មកគណបក្សសង្គ្រោះជាតិបានសម្រេចចិត្តធ្វើពហិការចូលរដ្ឋសភាជាច្រើនដង នៅពេលនោះដោយមានការព្រួយបារម្ភពីសន្តិសុខស្របច្បាប់ ។ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រ នៃការធ្វើពហិការចូលរដ្ឋសភា ហាក់ទទួលបានផលតិចណាស់ ជាមួយនឹងសម្លេងភាគច្រើនក្នុងរដ្ឋសភា គណបក្សប្រជាជនកម្ពុជា អាចធ្វើការងារតាក់តែងច្បាប់គេតាមដែលគេចង់បាន។[63] ទោះយ៉ាងណាក៏ដោយ គេអាចយល់បានថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មិនមានឆន្ទៈចូលរួមកិច្ចប្រជុំរដ្ឋសភា ដោយតំណាងរាស្ត្រពីររូបរបស់គណបក្សខ្លួនរងនូវអំពើហិង្សាគឺ លោក ញ៉យ ចំរើន និង លោក គង់ សភា។[64]

ចុងក្រោយ ដោយប្រទះនឹងឱកាសរិះគន់ទៅលើកង្វះគោលនយោបាយច្បាស់លាស់ គណបក្សសង្គ្រោះជាតិប៉ុន្មានឆ្នាំមុន បានព្យាយាមវិវឌ្ឍឲ្យមានដំណោះស្រាយគោលនយោបាយឲ្យច្បាស់លាស់សម្រាប់បញ្ហារបស់ប្រទេសកម្ពុជា និងសម្រាប់តួនាទីរបស់គណបក្សដែលអាច ជាជម្រើសគ្រប់គ្រងផ្សេងទៀតក្រៅពីគណបក្សប្រជាជនកម្ពុជា។ នៅដើមខែ សីហា ឆ្នាំ២០១៦ គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួនកំពុងនៅក្នុងដំណើរការបង្កើត "គណៈរដ្ឋមន្ត្រីស្រមោល" ដោយមានតំណាងរាស្ត្រឈរជា រដ្ឋមន្ត្រីផ្សេង ការប្រកាសនេះបានចេញមកជាមួយនូវសេចក្តីប្រកាសមានកម្រាស៦៧ ទំព័រ ដែលឆ្លើយតបនៅនឹងការរិះគន់ចំពោះកង្វះខាតនូវគោលនយោបាយជាក់លាក់របស់បក្ស។[65] ខណៈដែលការវិវត្តន៍នេះទទួលបានការស្វាគមន៍ តែគេនៅមិនទាន់មើលឃើញឲ្យឃើញថា ការណ៍នេះនឹងមានលទ្ធផលនៃការផ្លាស់ប្តូរច្បាស់លាស់ ឬគណបក្សនឹងធ្វើបែបណាទៀតនោះទេ។

---

[63] វង្ស សុខេង និងឆាល រ៉ូឡែត, 'សភាអនុម័តច្បាប់ស្តីកញ្ចប់ថវិក ខណៈបក្សប្រឆាំងធ្វើពហិកាបោះឆ្នោតគាំទ្រ', ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៥ http://bit.ly/2dpwfZb ។

[64] https://www.youtube.com/watch?v=NIqa5Mad7Sc.

[65] អាឡិច វីលៀមមីន និង សេក ឧត្តម, 'គណបក្សប្រឆាំងបញ្ចេញផែនការបង្កើតគណៈរដ្ឋមន្ត្រីស្រមោល' ខេមបូឌាដេលី ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៦http://bit.ly/2eWcsxk ។

ទន្ទឹមនឹងនេះ គណបក្សសង្គ្រោះជាតិ បន្តរយកផលប្រយោជន៍នៃការគាំទ្រ ពីប្រជាពលរដ្ឋកម្ពុជាក្រៅស្រុក ជាពិសេសនៅសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលី ដែលបានផ្តល់ហិរញ្ញវត្ថុជាច្រើនដល់គណបក្ស។ គណបក្សសង្គ្រោះជាតិបានចំណាយពេល និងកម្លាំងជាច្រើន ដើម្បីយកចិត្តរបស់ប្រជាជនកម្ពុជាក្រៅស្រុកក្នុងគោលបំណងឲ្យពួកគេរក្សាជំនួយ ដោយធ្វើការពន្យល់អំពីការមិនពេញចិត្តរបស់គណបក្សសង្គ្រោះជាមួយប្រទេសវៀតណាម និងបញ្ហាព្រំដែនដែលជាបញ្ហាសំខាន់របស់ប្រជាជនខ្មែរក្រៅស្រុក។ គណបក្សសង្គ្រោះជាតិបានទទួលប្រយោជន៍ពីការគាំទ្រដ៏ខ្លាំងក្លារបស់សហគមន៍អន្តរជាតិ បើទោះបីជាវិសាលភាពនៃជំនួយនៅមានមន្ទិលថា អាចជួយឲ្យមានការផ្លាស់ប្តូរនយោបាយនៅក្នុងប្រទេសឬយ៉ាងណាក៏ដោយ។ លោក សម រង្ស៊ី និងថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិផ្សេងទៀត បានចំណាយពេលវេលា និងកម្លាំងជាច្រើនឆ្នាំដើម្បីធ្វើដំណើរនៅរដ្ឋធានីនៃប្រទេសលោកខាងលិច និងថ្លែងអំពីរឿងរបស់ពួកគេទៅកាន់រដ្ឋាភិបាលបរទេស ដែលពេលនោះជាអ្នកដែលអាចបង្វែរបញ្ហា តាមរយៈសេចក្តីថ្លែងការណ៍ថ្កោលទោសទង្វើធ្វើទុក្ខបុកម្នេញរបស់គណបក្សប្រជាជនទៅលើគណបក្សសង្គ្រោះជាតិ ។

គណបក្សសង្គ្រោះជាតិ មានមូលដ្ឋានច្រើនដើម្បីចាប់ផ្តើមប្រកួតប្រជែងជាមួយគណបក្សប្រជាជន លើបញ្ហាគោលនយោបាយ និងព្រមទាំងបង្ហាញថាឲ្យឃើញថាពួកគេជារដ្ឋាភិបាលដែលមានសមត្ថភាព និងត្រៀមរួចជាស្រេច។ ច្បាស់ណាស់ដែល គណបក្សសង្គ្រោះជាតិបានធ្វើឲ្យអ្នកគាំទ្ររបស់ខ្លួនខកចិត្ត ចាប់តាំងពីឆ្នាំ ២០១៣ ជាឆ្នាំដែលមានទំហំនៃការរំពឹងទុក និងក្តីសង្ឃឹមខ្ពស់ ដោយគណបក្សបានធ្វើឲ្យបាត់បង់នូវក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋ និងយុវជន ខណៈដែលបានធ្វើឲ្យបាត់បង់នូវមូលដ្ឋាននៃរបស់ខ្លួនផងដែរ ជាពិសេសពន្លឺនៃគណបក្សនយោបាយថ្មី ដូចជាគណបក្សប្រជាធិបតេយ្យមូលដ្ឋាន និងគណបក្សប្រជាធិបតេយ្យសង្គមសំបុកឃ្មុំ ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១៥។[66]

## ៥.ហានិភ័យ

ដោយទុកចោលវប្បធម៌សន្ទនា មេដឹកនាំទាំងពីរបានងាកទៅបន្តវប្បធម៌ចាស់ដែលធ្លាប់អនុវត្តកន្លងមកអស់ជាច្រើនឆ្នាំ ដែលពុំបានជួយដល់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឲ្យប្រសើរឡើងនោះទេ។ ម្យ៉ាងវិញទៀត ក្រុមអ្នកនយោបាយកាន់តែស្ថិតនៅឆ្ងាយពីអ្នកបោះឆ្នោតឲ្យខ្លួន ខណៈដែលកិច្ចពិភាក្សាលើបញ្ហាគោលនយោបាយសំខាន់ៗមិនត្រូវបានយកចិត្តទុកដាក់។ ដូច្នេះហើយ ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើងមានអារម្មណ៍ថាខ្លួនមិនត្រូវបានយកចិត្តទុកដាក់ឲ្យបានដិតដល់ ប្រសិនបើអ្នកនយោបាយខ្មែរនៅតែបន្តការគេចវេះពីការដេញដោលគ្នាលើបញ្ហាសំខាន់ៗរបស់ជាតិ។

---

66 ដេវីត ហាត់ , 'តួអង្គទាំងបួន៖ គណបក្សនយោបាយថ្មីនៅកម្ពុជា', *Southeast Asia Globe* ,ថ្ងៃទី១ ខែ តុលា ឆ្នាំ២០១៥ http://bit.ly/2dC8NGj

យុវជនកម្ពុជា ដែលបានប្រមូលផ្តុំគ្នាកាលពីឆ្នាំ២០១៣ ដោយប្រើប្រាស់ទូរសព្ទដៃទំនើប និងបណ្តាញទំនាក់ទំនងសង្គមទំនើបៗ នៅតែបន្តទាមទាឲ្យមានការពិភាក្សាលើប្រធានបទនយោបាយ និងគណនេយ្យភាពផ្នែកនយោបាយកាន់តែច្រើនថែមទៀត។ លើកលែងតែមានការទទួលស្គាល់ហានិភ័យ ត្រួតពិនិត្យយុទ្ធសាស្ត្រឡើងវិញ និងបង្កើតគោលនយោបាយជាក់លាក់ ទំនោររបស់មតិសាធារណជនដែលមានការកើនឡើងឆាប់រហ័ស ជាពិសេសក្នុងចំណោមអ្នករស់នៅទីក្រុង និងយុវជន អាចមានសន្ទុះនៃរលកបាតុកម្មថ្មី ការប្រែប្រួលយ៉ាងខ្លាំងនៃទិដ្ឋភាពនយោបាយ និងអំពើហិង្សាក្នុងកំឡុងពេលបោះឆ្នោតជាតិ ឆ្នាំ២០១៨។

ហានិភ័យនៃការបន្តស្ថានភាពបច្ចុប្បន្នមានច្រើន។ នៅពេលដែលប្រជាពលរដ្ឋមានអារម្មណ៍ថាមិនត្រូវបានគេយកចិត្តទុកដាក់ និងសិទ្ធិនយោបាយត្រូវបានដកហូត លទ្ធភាពដែលអាចកើតឡើងមហាបាតុកម្ម ឬកូដកម្ម ដោយសារតែការស្រងាកចិត្ត និងកំហឹងរបស់ប្រជាពលរដ្ឋ អាចនឹងកើតឡើងម្តងទៀត។ បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០១៣ ប្រជាពលរដ្ឋរំពឹងថាសំឡេងរបស់ពួកគេនឹងត្រូវគេយកចិត្តទុកដាក់ស្តាប់ និងទស្សនៈរបស់ពួកគេត្រូវបានពិចារណា។ ខណៈដែលរនាំងនៃសេចក្តីភ័យខ្លាច បានគ្របដណ្តប់លើប្រទេសជាថ្មីម្តងទៀត ដែលពេលនេះកាន់តែពិបាកត្រឡប់ទៅរកសភាពដើមឡើងវិញ។ ប្រជាពលរដ្ឋដែលធ្លាប់រីករាយនឹងសេរីភាពកន្លងមក ប្រសិនបើពួកគេយល់ថាខ្លួនត្រូវបានដកហូតសិទ្ធិនយោបាយដោយអយុត្តិធម៌ ឬអ្នកតំណាងរបស់ខ្លួនមិនមានឆន្ទៈក្នុងបំពេញតួនាទីនោះឲ្យប្រជាពលរដ្ឋនោះ ហានិភ័យកាន់តែខ្ពស់ ដោយកំហឹងនឹងកាន់តែកើនខ្លាំងឡើងៗម្តងទៀតព្រោះគ្មានសេចក្តីសង្ឃឹមតទៅទៀត។

ស្ទើតែជៀសពុំរួច កំហឹងអាចនាំទៅដល់ការប្រើប្រាស់ហិង្សា ជាពិសេសប្រទេសដូចជាកម្ពុជា ដែលអាជ្ញាធរធ្លាប់តែបង្ហាញទំនោរក្នុងការប្រើប្រាស់កម្លាំង ទាំងកម្លាំងសន្តិសុខផ្លូវការ និងមិនផ្លូវការ... ហានិភ័យមួយទៀត គឺសាធារណជន និងបាតុករអាចបង្កហិង្សា។ ករណីនេះហើយដែលជាហេតុផលរបស់រដ្ឋាភិបាលដែលមិនអនុញ្ញាតទុកឲ្យស្ថានភាពបែបហ្នឹងបន្តយូរទៅទៀតបាន ដោយសារតែសម្ពាធអាចនឹងកើនឡើងដល់កម្រិតមួយអាចបង្កគ្រោះថ្នាក់។ ប្រជាពលរដ្ឋត្រូវការក្តីសង្ឃឹមនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងគណបក្សនយោបាយដែលអាចបម្រើផលប្រយោជន៍របស់ពលរដ្ឋ ព្រមទាំងក្តីសង្ឃឹមនៃដំណើរការលទ្ធិប្រជាធិបតេយ្យ។

នយោបាយនៅកម្ពុជានៅតែមានភាពផុយស្រួយនៅឡើយ។ ហេតុនេះហើយយុទ្ធសាស្ត្រដែលត្រឹមត្រូវនិងមានតុល្យភាព អាចនឹងកសាងទំនុកចិត្ត មិនត្រឹមតែជាមួយនឹងអ្នកនយោបាយមកពីគណបក្សទាំងសងខាងទេ ថែមទាំងបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋផងដែរ។ ជាងនេះទៀត កាលណាប្រជាពលរដ្ឋអាចរីករាយជាមួយនឹងសេរីភាពលើប្រព័ន្ធអ៊ីនធឺណែតកាន់តែច្រើន ទាំងការទទួលបានព័ត៌មាន មតិពីមិត្តភក្តិរបស់ពួកគេ និងការបញ្ចេញមតិផ្ទាល់ខ្លួនផងនោះ ការប្រមើមើលរឹតតែមិនអាចដឹងថាស្ថានការណ៍នឹងផ្លាស់ប្តូរបែបណានោះទេ។ ហានិភ័យនៃការផ្លាស់ប្តូរស្ថានការណ៍អាចកើតមានគ្រប់ពេលវាលា។

## ៦. សេចក្តីសន្និដ្ឋាន

យុវជនខ្មែរដែលបានប្រមូលផ្តុំគ្នាតាមដងផ្លូវដោយគ្មានភ័យខ្លាចកាលពីឆ្នាំ២០១៣ គឺមិនទាន់ទៅណាទេ។ សំឡេងរបស់ពួកគេត្រូវបានស្តាប់កាន់តែច្រើននៅលើបណ្តាញសង្គម។ ចាប់តាំងពីការបោះឆ្នោតឆ្នាំ ២០១៣ យុវជនខ្មែរកាន់តែចូលរួមច្រើន និងទទួលបានព័ត៌មានកាន់តែច្រើនទាក់ទងនឹងបញ្ហានយោបាយ តាមរយៈការប្រើប្រាស់បណ្តាញសង្គម និងទូរសព្ទទំនើប។

ប៉ុន្តែមុនការបោះឆ្នោតជាតិឆ្នាំ២០១៨ខាងមុខនេះ ជាពិសេសការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ កម្ពុជាត្រូវការយុវជនទាំងនេះ ដើម្បីចាប់ផ្តើមទាមទារឲ្យកាន់តែខ្លាំងក្លានូវគណនេយ្យភាព និងដំណោះស្រាយគោលនយោបាយពីមេដឹកនាំគណបក្សនយោបាយរបស់ពួកគេ... បើមិនដូច្នេះទេ ប្រទេសកម្ពុជានឹងមិនអាចឆ្ពោះទៅមុខឲ្យផុតពីអតីតកាលចាស់បាននោះទេ។ ប្រសិនបើមេដឹកនាំគណបក្សបរាជ័យក្នុងការឆ្លើយតបចំពោះបញ្ហាទាំងនោះ និងបន្តប្រើនយោបាយបែបអវិជ្ជមានចាស់គំរិលដដែលដូចកាលពីប៉ុន្មានខែមុននេះ យុវជនខ្មែរត្រូវឈោមថ្មីទៅក្នុងគណបក្សនយោបាយធំទាំងពីរ ព្រមទាំងគណបក្សនយោបាយតូចៗដែលទើបតែបង្កើតឡើងក្នុងពេលថ្មីៗនេះ។ នេះជាពេលវេលាសមស្រប សម្រាប់យុវជនក្នុងការងាកចេញពីស្រមោលនយោបាយចាស់ ជម្លោះភាពភ័យខ្លាច ហ៊ានប្រឈមនឹងមេដឹកនាំរបស់ខ្លួ និងរុញកម្ពុជាទៅកាន់យុគសម័យកាលថ្មីមួយទៀតនៃលទ្ធិប្រជាធិបតេយ្យ។

យ៉ាងណាក៏ដោយ លទ្ធិប្រជាធិបតេយ្យមិនមែនគ្រាន់តែការបោះឆ្នោតនោះទេ។ លទ្ធិប្រជាធិបេតយ្យជាការគោរពបាននូវនីតិរដ្ឋ គោរពសិទ្ធិសេរីភាពមូលដ្ឋាន សិទ្ធិខាងការបញ្ចេញមតិ ប្រមូលផ្តុំ និងសមាគម សង្គមស៊ីវិលដែលរឹងមាំ និងរស់រវើក ការបែងចែកអំណាចទាំងបីរបស់រដ្ឋយ៉ាងពិតប្រាកដ តម្លាភាព និងគនេយ្យភាព និងការអភិវឌ្ឍសេដ្ឋកិច្ចដែលត្រូវបានចែករំលែកឲ្យបានគ្រប់ៗគ្នា។ របៀបលេងនយោបាយប្រជុយប្រជានៅកម្ពុជា ជាឧបសគ្គក្នុងការដាក់ចេញនូវគោលនយោបាយដែលជាដំណោះស្រាយពិតប្រាកដចំពោះបញ្ហាសំខាន់ៗរបស់ជាតិ។

យ៉ាងណាក្តីមានហេតុផលជាច្រើន ដែលយើងត្រូវមានសុទិដ្ឋិនិយម។ ប្រជាពលរដ្ឋខ្មែរក្មេងៗ ដែលប្រកបដោយស្មារី និងឆន្ទៈនយោបាយខ្ពស់ អាចនាំមកនូវគំនិត និងទស្សនវិស័យថ្មីៗដាក់លើតុ និងជួយអ្នកជំនាន់មុនក្នុងបង្កើតចក្ខុវិស័យវិជ្ជមានសម្រាប់ប្រទេស តាមរយៈការជជែកពីគោលនយោបាយ និងដំណោះស្រាយ។ ប្រសិនបើគណបក្សនយោបាយទាំងពីរអាចទទួលយកយុគសម័យកាលថ្មី ធ្វើការផ្លាស់ប្តូរនយោបាយដោយងាកចេញពីការផ្តោតលើបុគ្គល និងភាពភ័យខ្លាចទៅរកគោលនយោបាយ និងគុណតម្លៃ កំណែទម្រង់ស្ថាប័នជុំវិញបញ្ហារបស់ពលរដ្ឋ ផ្ទត់គំនិត និងរចនាសម្ព័ន្ធ នោះកម្ពុជាអាចនឹងបំពេញដោយសក្តានុពលរបស់ខ្លួនជាមិនខាន។ ការបោះឆ្នោតឆ្នាំ ២០១៨ នឹងជាវិញ្ញាសានៃកំណែទម្រង់ និងការវិវឌ្ឍ។